# វគ្គ អារម្មណ៍

ធ្លាប់ទេ? អារម្មណ៍ដែលថា មនុស្សម្នាក់នេះយើងធ្លាប់បានចួបគេពីមុនមក...តែគ្មានទេ នឹកមិនឃើញឡើយ។ មើលពីក្រោយទៅ គេមានស្មាធំទូលាយសមនឹងសំឡេងក្រអួនដែលកំពុងបង្ហើរ។

នេះជាកម្មវិធីសាកសំឡេងបេក្ខជនបេក្ខនារីដោយការច្រៀងស្ងួត។ ប្រសិនពួកគេជាប់ជម្រើស នឹងអាចបានចូលទៅសាកផ្ទាល់ក្នុងស្ទូឌីយោទៀត។

គ្រប់គ្នាត្រូវសាកបែបនេះ គឺច្រៀងមិនមានភ្លេងនៅនឹងមុខមនុស្សប្រុសវ័យកណ្ដាលចរិតហំហាន មុខស្ងួតលក្ខណៈគ្មានមេឡូឌីម្នាក់។ គ្នាខំច្រៀងសឹងអីហើយ គាត់នៅធ្វើជាចុចទូរសព្ទអូសចុះឡើងធ្វើវាហី។

ខ្និលផ្ដោតអ្វីលើមនុស្សគ្មានចិត្ត នាងគិតមករកមនុស្សដែលធ្វើឱ្យមានអារម្មណ៍ពិសេសវិញល្អជាង។

គេនៅតែច្រៀងបន្ត។ សរសៃប្រសាទស្រីស្រាប់តែចាប់ផ្ដើមពាក់ព័ន្ធនឹងបេក្ខជនម្នាក់នេះខុសពីអ្នកមុនៗ។

មិនមានអីចម្លែកនោះទេ សម្រាប់ការជ្រើសរើសយកបេក្ខជនថ្មីចូលច្រៀង«អាល់ប៊ុមរឿង» ដ៏ពិសេសរបស់ផលិតកម្ម ហ្គោលប្រាដឺ ដែលជាផលិតកម្ម មានទីផ្សារបទចម្រៀងឌីជីថល ល្បីរន្ទឺ ធ្លាប់កសាងកេរ្ដិ៍ឈ្មោះឱ្យតារាចម្រៀងជាច្រើននៅក្នុងព្រះរាជាណាចក្រមួយនេះ។ ពេលនេះ G-Brothers ក៏ជាផលិតកម្មដែលរកចំណូលបានច្រើនបំផុតនៅលើបណ្ដាញយូធូបទៀត។

ធម្មតាឋានៈត្រឹមតែបេក្ខជន ពិតណាស់រមែងខុសឆ្ងាយពីឋានៈតារាចម្រៀងល្បីឬសូម្បីតែអាចប្រៀបទៅនឹងអ្នកដែលបានឱកាសឱ្យចូលទៅសាកល្បងសំឡេងនឹងស្ទូឌីយោ។ ទោះយ៉ាងណាក៏មិនស្មានថា ក្រុមហ៊ុនយក្សលំដាប់ប្រទេសមួយនេះ បានបង្ហាញនូវចរិតឆ្មើងកន្ទ្រើងដាក់ធនធានមនុស្សថ្មីៗតាំងពីដំបូងទៅហើយ។

នាងឈ្ងោកសរសេរ Note ដែលជាទម្លាប់នៃកវីមិនទាន់ល្បីដូចនាង...គ្រប់យ៉ាងដែលបានឃើញ រមែងជាមេរៀន!

«ធ្វើខ្លួនឯងទេណ៎ា កុំខឹងដែលខ្ញុំ Note! ឱ្យមនុស្សប្រុសមុខសោះកក្រោះ ដៃកាន់ទូរសព្ទបំបាក់មុខអ្នកគ្នាខំមកសាកសំឡេងកណ្ដាលជំនុំចំណោម ឱ្យគ្នាអង្គុយច្រៀងកណ្ដាលវាល អ្នកណាៗ

ក៏ឃើញ! សំណាងហើយមនុស្សម្នាក់នេះ ដូចជាផ្ទង់អារម្មណ៍បានយ៉ាងល្អ ច្រៀងបានត្រូវចង្វាក់ ទោះបីជាគ្មានភ្លេង! ដាក់មនោសញ្ចេតនាជ្រៅទោះបីជាមិនឃើញមានអ្នកយកចិត្តទុកដាក់ស្ដាប់! តស៊ូឡើងទាំងគ្មានសញ្ញាបង្ហាញថាមានគេចង់ស្វាគមន៍សំឡេងខ្លួនមកក្នុងពិភពសិល្បៈខ្មែរ! ហ៊ឹម.....»

«ទៅចុះប្អូន!»

បុរសវ័យកណ្ដាលនិយាយបីម៉ាត់នេះឈឺប កាត់ផ្ដាច់បទចម្រៀងដែលកំពុងតែពីរោះ ឱ្យត្រូវរុះរោយស្វាត់បង់ទៅកណ្ដាលទី ធ្វើឱ្យយុវជនបញ្ឈប់សំឡេង ហើយដៃនាងក៏ផ្អាកលែងNote។

គេនិយាយរដាក់រដុបវិញ៖

«អ៊ីចឹង! ខ្ញុំនៅរង់ចាំលទ្ធផលឬក៏យ៉ាងម៉េចបង?»

«បើសិនជាប្អូនត្រូវបានជ្រើសរើសនឹងមានអ្នកខលទៅ!»

គាត់តបឆ្លើយមិនរវល់ថា បេះដូងអ្នកមកប្រលងនេះកំពុងតែប្រជែងនឹងសម្ពាធថប់បារម្ភកម្រិតណាទេ។ គេនោះបានងើបនិងបែរមុខមកហើយ។ នាងជាមនុស្សស្រី នាងក៏ចង់ធ្វើចរិតស្រីស្អាត មិនចាប់អារម្មណ៍ចំពោះគេអ្វីដែរ ប៉ុន្តែបេះដូងជាអ្នកសិល្បៈដូចគ្នានិងភាពស្មោះត្រង់នៅក្នុងវិជ្ជាជីវៈរបស់នាង បានរំញោចដាស់នាងឱ្យលើកមេដៃមួយសំដៅទៅកាន់គេភ្លាម ជាសញ្ញាបង្ហាញថា«ច្រៀងបានល្អ!»។

«គិតពីគេ គិតពីចិត្តអ្នកផង» ជាចរិតលក្ខណៈពិតរបស់នាង ។ នាងមានឈ្មោះលក្ខិណា អ៊ុន អង្គលក្ខិណា តែមនុស្សគ្រប់គ្នាដែលស្គាល់ស្និទ្ធ ច្បាស់ជាគេហៅថាស្រីអង្គឬក៏ស្រីណា។

អង្គចូលចិត្តភ្លេងតាំងពីតូចៗមក។ ការចូលចិត្តនេះមិនមានទាស់ខុសអ្វីនោះទេ ទោះបីជាពេលខ្លះធ្វើឱ្យយើងមើលទៅដូចជាមនុស្សមិនមាត់មិនក មិនសូវមានសមត្ថភាពទំនាក់ទំនងទៅកាន់មនុស្សជុំវិញខ្លួន ប៉ុន្តែបេះដូងអង្គនៅតែជោកជាំទៅដោយភាពស្មោះស្ម័គ្រជាមួយនឹងសេចក្ដីល្អ។

មេដៃមួយនេះ បានធ្វើឱ្យគេផ្ទៀងសម្លឹងមកតែក៏មិនបានញញឹមទេ។

នៅពេលដែលគេក្រោកឈរឡើង គឺខ្ពស់ជាងដែលនាងគិតទៅទៀត។ រូបរាងរបស់គេកម្ពស់កំពរ សម្បុរសម្បកនេះកែវភ្នែកពោរពេញទៅដោយមនោសញ្ចេតនា ទឹកមុខបែបនេះ

កិរិយានឹងនរយ៉ាងសុភាពរាបសាបែបនេះ បើបូកបញ្ចូលជាមួយនឹងសូរសំឡេងច្រៀងអម្បាញ់មិញ អង្គសឹងតែទាយមិនបាច់គិតច្រើនថាគេនឹងជាប់នៅ G-Brothers ។

«ប៉ុណ្ណឹងបានហើយ! អ្នកដែលនៅសល់អាចនៅមកសាកសំឡេងថ្ងៃស្អែកទៀត!»

អង្គកាត់វគ្គមមើមមាយចេញ ងាកមកសម្លឹងជុំវិញខ្លួន។ យល់ណាស់ អារម្មណ៍ដែលខំមកអង្គុយចាំមួយព្រឹក ទីបំផុតគេក៏ដេញឱ្យត្រលប់ទៅផ្ទះវិញ«សិន»។ ប៉ុន្តែក៏ល្អដែលមិនចាំបាច់ត្រូវអង្គុយច្រៀងដូចច្រៀងឱ្យពាហនៈស្តាប់ ខណៈអ្នកដែលត្រូវមកស្តាប់ ត្រូវមានភារៈមកជ្រើសរើស សម្រេចចិត្តនោះជាប់រវល់ជាមួយទូរសព្ទរបស់គាត់ មិនដឹងជាតាមដានរឿងឯកជនរបស់អ្នកណា ឬមួយក៏តាមដានព័ត៌មានស្រ្តីមេផ្ទះ ប៉ុន្តែគាត់មិនបានបំពេញតួនាទីរបស់គាត់នៅនឹងកន្លែងនេះទេ។

«អ្ហែ៎អូន! បងប្រាប់ហើយ ថាស្អែកចាំមកទៀត!»

គ្រប់គ្នាចាកចេញអស់ហើយ ដូច្នេះអ្នកដែលគាត់កំពុងនិយាយជាមួយគឺនាង។

«មិនមែនទេ! ខ្ញុំរង់ចាំជួបបងពិស្តា!»

«ពិស្តាមកពីSingaporeវិញហើយ?»

«ចាស៎ ខ្ញុំបានទាក់ទងជាមួយគាត់តាមឆែត! គាត់ឱ្យខ្ញុំមកចាំនៅនេះ!»

«អូខេចាំខ្ញុំជួយសួរឱ្យ! ហើយឈ្មោះអីដែរ?»

«ចាស៎ លក្ខិណា!»

មនុស្សប្រុសម្នាក់នេះ មើលនាងពីលើដល់ក្រោមសិនទើបសម្រេចចិត្តចុចទូរសព្ទ។

អាកប្បកិរិយាដែលនាងមិនពេញចិត្តបានកើតមានឡើងជាលើកទីពីរ។ ក្នុងនាមអ្នកទទួលភ្ញៀវ ក៏ជាអ្នកចាំទ្វារដំបូងគេនៃផលិតកម្មដ៏ធំមួយ គួរតែអាចធ្វើឱ្យអ្នកគ្រប់គ្នាដែលបានមកដល់ទីនេះមានអារម្មណ៍ពោរពេញទៅដោយគុណតម្លៃនិងមនោសញ្ចេតនា។ កុំថាដល់ស្រឡាញ់ បើមិនចាំបាច់ក៏គាត់មិនត្រូវប្រើក្រសែភ្នែកនិងឫកពានៃទំនាក់ទំនងដ៏ហួសសម័យកាលបែបនេះមកស្វាគមន៍ភ្ញៀវដែរ។

ទៀត! អង្គចង់បំភ្លេចចោលមនុស្សនេះ ទុកឱ្យគាត់ធ្វើការរបស់គាត់សិនទៅ ដោយងាកទៅរកបុរសម្ចាស់សំឡេងអម្បាញ់មិញ។

កវីស្រីនិងជាអ្នកភ្លេងដែលគ្មានគេស្គាល់ដូចនាង ពិតណាស់មានការយល់ចិត្តអ្នកដែលមានទេពកោសល្យ តែនៅមិនទាន់ល្បី។ ពាក្យថា«មិនទាន់ល្បី»បង្ហាញជំនឿចិត្តសម្ងាត់មួយដែលតរុណីយើងជឿថា គេនឹងល្បី។

ភ្នែកស្រីបាញ់ទៅដល់ជណ្ដើរចំពេលបុរសនោះរៀបនឹងចុះ តែហាក់គេនឹកឃើញពីអ្វីម្យ៉ាងក៏មិនដឹង បានជាដាច់ចិត្តបែរមកវិញ ហើយសម្លឹងនាងតាមរយៈស្មាខាងឆ្វេងរបស់គេ។

ទីបំផុតគេញញឹមហើយ!

ម្រាមទាំងអស់នៃដៃស្ដាំរបស់គេ លើកមកជាសញ្ញាបង្ហាញថា«ថ្ងៃក្រោយជួបគ្នា»។ អស្ចារ្យមែនទេតើ! ម្នាក់ចុចព្យាណូបានល្អគឺ«អង្គ» ម្នាក់ទៀតដែលច្រៀងយ៉ាងផ្អែមគឺ«គេ» បែរជាមកប្រើភាសា«គ»ដាក់គ្នាទៅវិញទៅមក។

នេះគឺជាបទពិសោធថ្មីទៀតនៅក្នុងនាមជាកវីនិពន្ធម្នាក់។ នាងញញឹមតបនឹងចងចាំគេទុក។

ដោយនៅមិនទាន់មានគេស្គាល់ ប៉ុន្តែខ្ញុំស្គាល់ខ្លួនឯង ខ្ញុំដឹងថាមានរឿងច្រើនទៀតដែលខ្ញុំត្រូវយល់ឱ្យច្បាស់រវាងសំឡេងហើយនិងអត្ថន័យនៃភាពគ្មានសំឡេង។

«ពិស្ដាចាំនៅជាន់ទីប្រាំមួយ អាចឡើងតាមជណ្ដើរនោះ!»

«ចាស អរគុណពូ!»

គាត់ហាក់ភ្ញាក់នៅពេលដែលឃើញនារីយើងហៅគាត់ថា«ពូ» ព្រោះគាត់ហៅនាងថា«អូន» ប៉ុន្តែអង្គទំនងជាមិនរវល់ទេ ពីព្រោះសកម្មភាពរបស់គាត់ គឺមិនរវល់ជាមួយអ្នកគ្រប់គ្នាមុន។ កវីស្រីដកដង្ហើមយូរ ដែលទីបំផុតទៅបានចាកចេញពីបន្ទប់រង់ចាំមួយនេះ ឆ្ពោះទៅរកជណ្ដើរយន្តនិងចុចឡើងទៅជាន់ទីប្រាំមួយ។

បងពិស្ដា នាងធ្លាប់តែជួបតាមឆែតនិងធ្លាប់តែឃើញគាត់តាមរយៈទស្សនាវដ្ដីធំៗពីព្រោះថា គាត់ជាអ្នកគ្រប់គ្រងការផលិតចម្រៀងល្បីម្នាក់សម្រាប់ផលិតកម្មមួយនេះ។

មើលទៅគាត់មានលក្ខណៈរួសរាយរាក់ទាក់ ហើយដើរមករង់ចាំអង្គដល់ជណ្ដើរយន្តតែម្ដង។

លក្ខណៈទំនាក់ទំនងរបស់គាត់ពិតជាគួរឱ្យគោរព។

«អង្គលក្ខិណាមែនទេ?!»

«ចាសបង ខ្ញុំនេះឯង!»

«អូខេ! តស់!»

គាត់នាំផ្លូវធីតាយើងចូលដល់កូនបន្ទប់តូចបំផុតមួយ ដែលបិទប្រតាកពេញទៅដោយពាក្យស្លោកសិល្បៈល្អៗដែលបន្សល់ទុកដោយតន្ត្រីករសំខាន់ៗលើពិភពលោក ដូចជា "Works of art make rules; rules do not make works of art." – Claude Debuss និង "You can't knock on opportunity's door and not be ready." – Bruno Mars។

បន្ទប់នេះអាចដាក់បានតែតុធំរបស់គាត់មួយនិងកៅអីចំនួន២ មានន័យថាគាត់ជាមនុស្សរវល់ច្រើនជួបភ្ញៀវនិយាយគ្នាភ្លាមៗចូលសាច់ការដោយមិនមានបដិសណ្ឋារកិច្ចអ្វីហ៊ឺហាអឹកអធិកច្រើននោះទេ។

«បងបានឃើញបទភ្លេងរបស់លក្ខិណាហើយ! ស្តាប់ពីរបីដង បងគិតថាល្អគួរសម!»

កវីសើចស្ងាញបញ្ចេញធ្មេញមកក្រៅ ព្រោះក្របានឮអ្នកល្បីណានិយាយពាក្យបែបនេះមកកាន់ខ្លួន។ បងពិស្តានៅឈរនៅឡើយ ខណៈនាងអង្គុយចាំស្តាប់។ គាត់កំពុងរុករើរកឯកសារចុះឡើង ឡើងចុះ ទំនងជារវល់ និងស្មុគខ្លាំងលើការងាររបស់គាត់។

ទោះយ៉ាងណា អង្គមានអារម្មណ៍ពេញចិត្តបុគ្គលិកលក្ខណៈអាជីពរបស់គាត់ណាស់។

«ឥឡូវហ្នឹង យើងកំពុងតែចេញត្រៀមចេញនូវសាច់រឿងមួយពេញលេញ ដែលត្រូវការបទចម្រៀងយ៉ាងហោចណាស់ម្ភៃប្រាំបទណ៎ាលក្ខិណា! សាច់ភ្លេងនិងLyric ត្រូវបម្រើសាច់រឿងកាលពីដើមរហូតដល់ចប់ ហើយបង្ហាញចរិតតួអង្គឯកនិងដំណោះស្រាយរបស់ពួកគេ!!»

គាត់អង្គុយចុះឃើតៗសម្លឹងនាងដែលនៅពីមុខ។ ទឹកមុខតរុណីនេះពិតជាបញ្ជាក់ពីមនោសញ្ចេតនាជឿទុកចិត្ត កោតគោរព និងកំពុងតាមស្តាប់គាត់ដោយយកចិត្តទុកដាក់ ជាមួយអំណរពេញចិត្តជាខ្លាំងផង។

មនុស្សប្រុសវាចាបន្ត៖

«បងសម្រេចចិត្តថា លក្ខិណាអាចសាកល្បងជាមួយគម្រោងការនេះ!»

«ខ្ញុំអរណាស់បង! សូមអរគុណបងច្រើន! ប៉ុន្តែតើសាកល្បងបែបណាទៅ?»

«លក្ខិណាអាចត្រឡប់ទៅវិញ សិក្សាសាច់រឿង ហើយលក្ខិណាអាចត្រូវការពេលមួយចំនួនធ្វើការលើបទភ្លេង ពេលត្រលប់មកវិញយ៉ាងហោចណាស់មានបទចម្រៀង៣ទៅ៥បទ ដែលបម្រើឱ្យសាច់រឿងនៅក្នុងដំណាក់កាលណាមួយក៏បាន អាចបើកក្បាល អាចនៅពេលបែកបាក់គ្នា ឬត្រង់ណាក៏បានដែលលក្ខិណាយល់ថាទំនង! អ៊ីចឹងនៅពេលដែលម្ចាស់រឿងហើយនិងខាង

គណៈកម្មការវាយតម្លៃយល់ឃើញថា ភ្លេងនិងទំនុកទាំងអស់ហ្នឹងអាចទៅរួច យើងនឹងធ្វើកុងត្រាជាមួយគ្នាភ្លាម!»

«អូបង! ខ្ញុំរំភើបខ្លាំងណាស់បង! អ៊ីចឹងអាចឱ្យសាច់រឿងមកខ្ញុំសិនបានដែរ?!»

បងពិស្ដាកាន់សំណុំឯកសារមួយនៅនឹងដៃ តែគាត់នៅទីទើរមិនទាន់ហុចមកនៅឡើយទេ។ ទោះមាត់គាត់ឆ្លើយថា«អូខេ» តែគាត់មើលមកភ្ញៀចម្នាក់នេះ ដោយសភាពចង់បញ្ជាក់ពីអ្វីមួយសិន។

អ្វីនោះសំខាន់ណាស់បើតាមដែលនាងកាត់ស្មាន។

«នេះជាសាច់រឿងមិនទាន់ចេញ គ្រប់យ៉ាងត្រូវការលាក់ការណ៍សម្ងាត់! ហើយបងគិតថា

លក្ខិណាយល់អំពីរបៀបរបបនិងលក្ខខណ្ឌទំនុកចិត្តនៅក្នុងឧស្សាហកម្មសិល្បៈនេះហើយ!»

«ចាស៎បង ខ្ញុំធានាជូនបង!»

គាត់ញញឹមដោយជឿជាក់លើទឹកមុខគត់មត់របស់កវីក្មេងមុនពេលដាច់ចិត្តហុចសាច់រឿងមក។ ការងារបន្តរបស់អង្គ គឺលាអានយ៉ាងរហ័សនូវទំព័រដំបូង ទាំងភ្លេចឈឹងបណ្ដារឿងមិនសប្បាយចិត្តដែលបុរសវ័យកណ្ដាលខាងក្រោមបានបង្កើតឡើងមក។

ដោយពិនិត្យសាច់រឿងលន្លង់លន្លោចនាទំព័រទីមួយសែនទាក់បេះដូងទៅហើយ នាងភ្លេចគិតថា នាងបានបណ្ដោយឱ្យពិស្ដារង់ចាំ រហូតដល់គាត់ពោលមកសួរ៖

«ម៉េចដែរ?!»

អង្គលក្ខិណាឈប់អានដោយងើបមុខមកនិយាយ៖

«អំពីមនុស្សពីរនាក់បានជួបគ្នាភ្លាម ក៏ចាប់ផ្ដើមមិនអាចភ្លេចគ្នាបាន! ចាប់តាំងពីពេលដែលគេបានឃើញគ្នាដំបូងក៏មានប្រតិកម្មមនោសញ្ចេតនាក្នុងជីវិតយុវវ័យជ្រាលជ្រៅនិងខ្លាំងក្លា! ទោះបីថា ស្នេហាដំបូងមិនមែនមានន័យថាទំនាក់ទំនងនេះនឹងស្ថិតនៅបានឋិតថេរជានិច្ចនោះ

ទេ ប៉ុន្តែអាចក្លាយទៅជាតន្ត្រីដ៏ពីរោះពិសាមួយ អាចប្រាប់ដល់អ្នកដទៃទៀតឱ្យដឹងមុន អំពីបទពិសោធ មិនថាសប្បាយឬកើតទុក្ខព្រួយរបស់ពួកគេ ក៏អាចជាការលួងលោមនិងអាចជាមេរៀនជីវិតផងដែរ!»

«វិភាគល្អ! តែបងសួរមួយ! មានអ្នករិះគន់ថា បទភ្លេងរបៀបនេះ សមតែជាមួយមនុស្សវ័យក្មេងបានជាមិនអាចល្បីឈ្មោះបានយូរដូចបទជំនាន់ដើមបាន លក្ខិណាមានមតិអី?!»

សំណួររបស់បងពិស្ដាធ្វើឱ្យនាងនឹកឃើញអំពីទ្រឹស្ដីខ្លួនឯងដែលតែងកំណត់ថា តើតន្ត្រីអាចប្រាប់អ្នកស្ដាប់អំពីអ្វីខ្លះ?

ជាទូទៅ តន្ត្រីប្រាប់យើងច្រើនលើសការនិយាយឬសរសេរទៅទៀត គឺប្រាប់អំពីបុគ្គលិកលក្ខណៈរបស់នរណាម្នាក់ទស្សនវិជ្ជា ចំណេះដឹង និងមនោសញ្ចេតនា...។

ស្រីតបមួយៗ៖

«តន្ត្រីដែលយើងនិយមចូលចិត្តនៅពេលវ័យប្រហែល២០ឆ្នាំឬអាចថាក្នុងយុវវ័យ យើងនឹងស្រឡាញ់បទភ្លេងនោះពេញមួយជីវិតទៅមុខតែម្ដង!»

បងពិស្ដាលើកដៃស្ទាបចង្កាដូចកំពុងបន្តស្ដាប់មិនហ៊ានធ្វេស។ នេះបញ្ជាក់បានថា នាងកំពុងនិយាយដូចទៅនឹងអ្វីដែលគាត់កំពុង«ជឿ»។

អង្គផ្ដើមពន្យល់ទៀត៖

«បើបទភ្លេងមួយមិនល្បីបានយូរ មិនមែនដោយសារវាជាបទភ្លេងយុវវ័យទេ តែមកពីវាមិនទាន់ជាទំនុកភ្លេងល្អ! បើខ្ញុំមានពេលពីរសប្ដាហ៍ ខ្ញុំត្រលប់មកវិញជាមួយនឹងបទភ្លេងបីបទហើយ ខ្ញុំនឹងសាកល្បងសរសេរLyricមកផង!»

«អូខេ......! ប៉ុណ្ណឹងចុះ! បងនៅមានប្រជុំផ្សេងទៀត! តែ.....កុំភ្លេចណ៎ាលក្ខិណា! ការសម្ងាត់! រក្សាបានការសម្ងាត់និងគោរពសម្ដី ជាគុណតម្លៃសម្រាប់ធ្វើការយូរអង្វែងជាមួយគ្នាក្នុងសិល្បៈ!»

«ចាំបង! ទុកចិត្តចុះបង!»

មាណវីនេះក្ដាប់មាត់ដោយមានទំនុកចិត្ត។

រវល់យ៉ាងណា គាត់នៅតែក្រោកឈរជូនដំណើរអង្គ។ កិរិយា បុរសបានធ្វើឱ្យកវីស្រីលួចវិភាគ «មនុស្សល្បីឈ្មោះទាំងនៅក្មេង មានលទ្ធផលការងារធំ មានគេគោរពកោតសរសើរដើរតាមច្រើន មិនមែនកើតឡើងចៃដន្យទេ!»